ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៩.......សហវ....

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០០៧

លិខិតចូល

ថ្ងៃទី..០៥...ខែ..១១....ឆ្នាំ20០៧

# សេចក្តីណែនាំ

## ស្តីពី

## ការប្រើប្រាស់គណនីរដ្ឋនៅតាមប្រព័ន្ធធនាគារ របស់ ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព និងសាលាខេត្ត-ក្រុង

**យោង :** -តាមសំណើក្នុងលិខិតលេខ: ៤៦៩០សហវ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី របាយការណ៍ប្រមូលផ្តុំគណនីរដ្ឋ និងការបែងចែកប្រភេទគណនីរបស់ ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព និងសាលាខេត្ត-ក្រុង ដែលបានបើក និងកំពុងប្រើប្រាស់នៅធនាគារជាតិ នៃកម្ពុជា និងនៅតាមប្រព័ន្ធធនាគារពាណិជ្ជនានា ។

-ចំណារឯកភាពរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៧ ។

ក្រសួងសេដ្ឋកិច្ច និងហិរិញ្ញវត្ថុ សូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព គ្រប់សាលាខេត្ត-ក្រុង និងគ្រប់ប្រព័ន្ធធនាគារដូចខាងក្រោម :

១- គ្រប់ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាពទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុងទាំងអស់សហការ និងរាយការណ៍ដោយស្មោះត្រង់ជាប្រចាំ អំពីស្ថានភាពនៃការ បើក - បិទ និងចំនួនគណនីពិតប្រាកដរបស់ខ្លួននៅតាមប្រព័ន្ធធនាគារ ដោយបញ្ជាក់ពីសមតុល្យជាក់លាក់របស់គណនីនីមួយៗ ហើយផ្ញើមករតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង អោយបានទៀងទាត់នៅរាល់ដំណាច់ខែ ។

២- គ្រប់ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព ទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ត្រូវបិទគណនីប្រាក់បញ្ញើរបស់ខ្លួនទាំងអស់ដែលមិនដំណើរការ បើពុំនោះទេក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបិទគណនីទាំងនោះជាស្វ័យប្រវត្តិ ។

៣-ធនាគារជាតិ នៃកម្ពុជា និងគ្រប់ធនាគារពាណិជ្ជទូទាំងប្រទេស នឹងធ្វើការបង្កកគណនីប្រាក់បញ្ញើរបស់

ក្រសួង- ស្ថាប័ន មន្ទីរ-អង្គភាពទាំងអស់ ដែលបានបើកនៅតាមប្រព័ន្ធធនាគារជាបណ្តោះអាសន្នសិន ដោយលើកលែងតែគណនីប្រាក់បញ្ញើ ជាប្រាក់បៀវត្ស ជាហិរញ្ញប្បទានក្រៅគំរោង ជាហិរញ្ញប្បទានសំរាប់គំរោង និងគណនីកម្មវិធីកាត់បន្ថយបំណុលពហុភាគី (MDRI Program) ដើម្បីទុកអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការត្រួតពិនិត្យសិន ។ ក្រោយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការត្រួតពិនិត្យរួច ប្រសិនបើមានឃើញគណនីទាំងឡាយណាដែលមិនចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការបិទគណនីទាំងនោះ ហើយផ្ទេរសមតុល្យចូលទៅក្នុងគណនីទោលរបស់រដ្ឋាភិបាល ដែលគ្រប់គ្រងដោយធនាគារជាតិជាប្រាក់រៀលលេខ : ០១០០-៣៥-១២១១-T001 និងជាប្រាក់ដុល្លារអាមេរិកលេខ : ០១០២-៣៥-១២១១-T0២៣ នៅធនាគារជាតិ នៃកម្ពុជា ។

៤-រាល់ការបើកគណនីរបស់ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព ទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុងត្រូវសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សេចក្តីណែនាំនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទទួលបានសេចក្តីណែនាំនេះសូមគ្រប់ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព និងគ្រប់សាលាខេត្ត-ក្រុងមេត្តាជ្រាប និងចាត់ចែងអនុវត្តទៅតាមខ្លឹមសារណែនាំខាងលើអោយទទួលបានប្រសិទ្ធភាពខ្ពស់បំផុត

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន
ពាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
យករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព
សាលាខេត្ត-ក្រុង
ារជាតិនៃកម្ពុជា " ដើម្បីសូមមេត្តាផ្តល់កិច្ចសហការ "
នាគារពាណិជ្ជ " ដើម្បីសូមផ្តល់កិច្ចសហការ "
ារ-កាលប្បវត្តិ